គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

**ថ្ងៃព្រហស្បតិ៍ ៦រោច ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២**

**ភ្នំពេញ, ថ្ងៃទី២៥ ខែ មេសា ឆ្នាំ២០១៩**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលដោយសង្ខេបនៃការអង្កេតរដ្ឋសភាក្នុងនីតិកាលទី៥

## លទ្ធផលនៃការសង្កេត

តាមការសង្កេតឃ្លាំមើលពីដំណើរការរបស់រដ្ឋសភា និងតំណាងរាស្ត្រ ក្នុងរយៈពេល៥ឆ្នាំ (កញ្ញា២០១៣-មិថុនា ២០១៨)នៃនីតិកាលទី៥ គណៈកម្មាធិការខុមហ្វ្រែល (COMFREL) បានសង្កេតឃើញថា នៅដើមនីតិកាល រដ្ឋសភាបានជាប់គាំង និងខ្វះនីត្យានុកូលភាពក្នុងការបង្កើតរដ្ឋសភា ក្រោយការបោះឆ្នោត ពីខែកក្កដា ឆ្នាំ២០១៣ ដល់ខែកក្កដា ឆ្នាំ២០១៤ ដោយមានភាពចម្រូងចម្រាស់យ៉ាងខ្លាំងអំពីលទ្ធផលនៃការបោះឆ្នោត ពីសំណាក់គណបក្សដែលទទួលបានអាសនៈក្នុងការបោះឆ្នោត។ គណបក្សសង្គ្រោះជាតិ បានតវ៉ានឹងលទ្ធផលបោះឆ្នោត និងមិនព្រមចូលរួមជាមួយគណបក្សប្រជាជនកម្ពុជាក្នុងការបង្កើតរដ្ឋសភា នីតិកាលទី៥។ តែទោះយ៉ាងនេះក៏ដោយ រដ្ឋសភា នីតិកាលទី៥ បានដំណើរការរបស់ខ្លួនដោយឯកបក្ស និងខ្វះនីត្យានុកូលភាព ហើយបានបើកសម័យប្រជុំរបស់ខ្លួន ដើម្បីធ្វើការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តជូនសមាសភាពរាជរដ្ឋាភិបាល អាណត្តិទី៥។ រដ្ឋសភា ដែលមានតែគណបក្សប្រជាជនកម្ពុជា ក៏បានអនុម័តច្បាប់ដ៏ចម្រូងចម្រាសចំនួនបីទាក់ទងវិស័យតុលាការ និងច្បាប់ថវិកាជាតិគ្រប់គ្រងឆ្នាំ២០១៤។

ជាលទ្ធផលដែលបានមកពីការអង្កេតរបស់ខុមហ្វ្រែលក្នុងរយៈពេលមួយនីតិកាលទី៥នេះបានឱ្យដឹងថា មានគណបក្សពីរដែលទទួលបានសាសនៈក្នុងរដ្ឋសភា គឺគណបក្សប្រជាជនកម្ពុជាទទួលបាន៦៨អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ។ រចនាសម្ព័ន្ធដឹកនាំនៃរដ្ឋសភា មានប្រធាន អនុប្រធានទាំង២នៃរដ្ឋសភា រួមទាំងគណៈកម្មការអចិន្ត្រៃយ៍ ប្រធាន និងអនុប្រធានទាំង១០ នៃគណៈកម្មការជំនាញនានារបស់រដ្ឋសភាគឺត្រូវបានបង្កើត និងបែងចែកអំណាចក្នុងចំណោមគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា នៅខែសីហា ឆ្នាំ២០១៤ ជាពិសេស ប្រធាន និងអនុប្រធានទី២រដ្ឋសភា ត្រូវបានដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ចំណែកឯអនុប្រធានទី១នៃរដ្ឋសភា ដឹកនាំដោយគណបក្សសង្គ្រោះជាតិ។

នៅក្រោយការបោះឆ្នោត ឆ្នាំ២០១៣ រដ្ឋសភាមានភាពរកាំរកូសខ្លាំង ដោយសារគណៈបក្សសង្គ្រោះជាតិដែលទទួលបាន៥៥អាសនៈក្នុងរដ្ឋសភាមិនចូលរួមប្រជុំដំបូងនៃរដ្ឋសភា និងបង្កើតរដ្ឋសភា នីតិកាលទី៥។ ការមិនចូលរួមនេះ ដោយសារតែគណបក្សសង្គ្រោះជាតិមិនសុខចិត្តនឹងលទ្ធផលនៃការបោះឆ្នោត។ រហូតដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ គណបកសង្គ្រោះជាតិក៏បានសម្រេចចូលចរចារជាមួយគណបក្សប្រជាជនកម្ពុជា ហើយបន្ទាប់មកក្រុមតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិក៏សម្រេចចិត្តចូលរដ្ឋសភានៅខែសីហា ឆ្នាំ២០១៤។ នៅពេលនោះក្បាលម៉ាស៊ីនដឹកនាំអង្គនីតិបញ្ញត្តិមួយនេះ ត្រូវបានរៀបចំឡើងវិញ ដោយមានការបែងចែកតួនាទីនៅក្នុងគណៈកម្មាធិការអចិន្ត្រៃនៃរដ្ឋសភាតាមរូបមន្ត៧ទល់៦។ គណៈកម្មការជំនាញថ្មីមួយទៀតត្រូវបានបង្កើត ដែលដឹកនាំដោយសមាជិករដ្ឋសភាពីគណបក្ស

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**

P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

សង្គ្រោះជាតិ។ គណៈកម្មការជំនាញថ្មីនោះ គឺគណៈកម្មការទី១០ មានឈ្មោះថា គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយដែលបានបំបែកចេញពីគណៈកម្មការជំនាញទី៤។

នៅក្នុងនីតិកាលនេះ តាមការសង្កេតឃើញថា អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំងប្រឈមនឹងការគំរាមកំហែង ករណីហិង្សា ការបំពារបំពានដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រពីសំណាក់ក្រុមមតិភាគច្រើនដែលកាន់អំណាច និងការដកតំណែង ដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ។ អភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ត្រូវបានស្ថាប័នតុលាការ និងរដ្ឋសភារំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដែលករណីទាំងនោះមានដូចជា:

- ក្នុងឆ្នាំ២០១៤ អ្នកតំណាងរាស្ត្ររបស់គណបក្សសង្គ្រោះជាតិចំនួន៧រូបត្រូវបានតុលាចាប់ឃុំខ្លួន និងចោទប្រកាន់។
- ក្នុងអំឡុងខែមេសា ឆ្នាំ២០១៦ ឯកឧត្តម អ៊ុំ សំអាន តំណាងរាស្ត្រមណ្ឌលសៀមរាបពីគណបក្សសង្គ្រោះជាតិត្រូវបាននគរបាលខេត្តសៀមរាបឃាត់ខ្លួន ហើយត្រូវតុលាការចោទប្រកាន់ចំនួនពីរបទល្មើស និងត្រូវបានតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាអនុម័តយល់ព្រមឲ្យក្រសួងមានសមត្ថកិច្ចបន្តនីតិវិធីចោទប្រកាន់ឃាត់ខ្លួន។
- នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឯកឧត្តម សម រង្ស៊ី ដោយចោទប្រកាន់ពីបទបរិហាកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានការរើសអើង ប្រព្រឹត្តនៅសារមន្ទីរជើងឯក សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨។ ជាមួយគ្នានេះ រដ្ឋសភាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានចេញសេចក្តីប្រកាសរបស់ខ្លួន ដែលមានខ្លឹមសារថា ឯកឧត្តម សម រង្ស៊ី ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា មណ្ឌលខេត្តកំពង់ចាម នីតិកាលទី៥។
- នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ឯកឧត្តម កឹម សុខា ត្រូវបានតំណាងរាស្ត្រគណបក្សកាន់អំណាចសម្រេចបោះឆ្នោតដកចេញពីតំណែងអនុប្រធានទី១នៃរដ្ឋសភា ហើយឯកឧត្តមក៏ត្រូវបានតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាសម្រេចឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការចោទប្រកាន់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ បន្ថែមទៀត នៅក្នុងសំណុំរឿងស្នេហាមួយ និងនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចចាប់ខ្លួនពាក់កណ្តាលអធ្រាត្រនៅគេហដ្ឋានរបស់ឯកឧត្តម ហើយត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់ពីបទ «សន្ទិដ្ឋិភាពជាមួយបរទេស» និងត្រូវបានតំណាងរាស្ត្រពីគណបក្សកាន់អំណាចបើកកិច្ចប្រជុំវិសាមញ្ញ ដើម្បីសម្រេចលើករណីឯកឧត្តម កឹម សុខា ដែលក្រសួងមានសមត្ថកិច្ចធ្វើការចោទប្រកាន់ ចាប់ខ្លួន និងឃុំខ្លួន។

លើសពីនេះទៀត នៅក្នុងខែតុលា ឆ្នាំ២០១៥ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ២រូប គឺឯកឧត្តម គង់ សភា និងឯកឧត្តម ញ៉យ ចំរើន ត្រូវបានក្រុមអ្នកតវ៉ា (ក្នុងបាតុកម្ម ដែលទាមទារឲ្យឯកឧត្តម កឹម សុខា ចុះចេញពីតំណែងអនុប្រធានទីមួយរដ្ឋសភា) ទាញចេញពីរថយន្តនៅមុខវិមានរដ្ឋសភា នៅពេលពួកឯកឧត្តមចាកចេញពីវិមានរដ្ឋសភា ហើយក្រុមអ្នកតវ៉ា (ដែលជាក្រុមអង្គរក្សរបស់នាយករដ្ឋមន្ត្រី) បានវាយបណ្តាលឲ្យរងរបួសយ៉ាងធ្ងន់ធ្ងរ។ ជាមួយគ្នានេះ អ្នកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភានៃគណបក្សប្រឆាំងដែលសកម្មក្នុងការតវ៉ាបញ្ហាព្រំដែនកម្ពុជា-វៀតណាម បានទទួលរងនូវចំណាត់ការផ្សេងៗពីតុលាការ និងពីរដ្ឋសភា ទៅលើសកម្មភាពរបស់ខ្លួន។ ឯកឧត្តម សុន ឆ័យ អនុប្រធានគណៈកម្មការទី២នៃរដ្ឋសភា ក៏ត្រូវបានថ្នាក់ដឹកនាំរដ្ឋសភាពីគណបក្សប្រជាជនកម្ពុជាគំរាមកំហែងដកចេញពីតំណែងក៏ព្រោះតែឯកឧត្តមបានធ្វើការចោទប្រកាន់ទាក់ទងបញ្ហាមិនប្រក្រតីក្នុងការចាយវាយថវិការបស់រដ្ឋសភា។

នៅក្នុងឆ្នាំ២០១៦ របាយការណ៍ខុមហ្វ្រែលបានរកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានទម្លាក់ អភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រគណបក្សប្រឆាំងបន្តរងការបំពារបំពាន ការបន្ថយតួនាទីរបស់តំណាងរាស្ត្រគណបក្សប្រឆាំង ព្រមទាំងលុបចោលថ្នាក់ដឹកនាំតំណាងរាស្ត្រ និងប្រធានក្រុមមតិភាគតិច។ ជាមួយគ្នានេះ តំណាងរាស្ត្រគណបក្សកាន់អំណាច បានអនុម័តច្បាប់ និងធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាលុបចោលក្រុមមតិភាគតិចទទួលស្គាល់ដោយច្បាប់។ មានការលើកទឹកចិត្ត តម្លើងឋានន្តរសក្តិដល់អ្នកដៃដល់ជាមន្ត្រីកម្លាំងប្រដាប់អាវុធនៃកងអង្គរក្ស ដែលបានប្រើអំពើហិង្សាលើតំណាងរាស្ត្រគណបក្សមតិភាគតិច។

ក្នុងឆ្នាំ២០១៧ របាយការណ៍ខុមហ្វ្រែលក៏បន្តរកឃើញថា ប្រសិទ្ធភាពរបស់រដ្ឋសភាត្រូវបានបន្តទម្លាក់ជាងឆ្នាំ២០១៦។ អ្វីដែលធ្ងន់ធ្ងរក្នុងរយៈពេលនេះ គឺតំណាងរាស្ត្រនៃគណបក្សកាន់អំណាចបានផ្តួចផ្តើម និងសម្រេចជាឯកបក្សក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ដើម្បីផ្អាក បញ្ឈប់ ឬរំលាយគណបក្សនយោបាយ និងប្រធាន និងថ្នាក់ដឹកនាំគណបក្សនយោបាយ ហើយជាលទ្ធផលនៃវិសោធនកម្មនេះ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំ និងជាដៃគូប្រជែងជាមួយគណបក្សកាន់អំណាចក្នុងការបោះឆ្នោតត្រូវបានរំលាយ។ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតទាំង៤ ដែលផ្តោតលើរូបមន្តថ្មីនៃការបែងចែកអាសនៈ មានផលប៉ះពាល់ជាអវិជ្ជមាន និងអយុត្តិធម៌ធ្ងន់ធ្ងរចំពោះសំឡេងម្ចាស់ឆ្នោត តំណាងឱ្យឆន្ទៈរបស់ម្ចាស់ឆ្នោត ដែលមិនឆ្លុះបញ្ចាំងអំពីសមាមាត្រសន្លឹកឆ្នោតនៃភាពជាតំណាង ក៏ជាបញ្ហាធ្ងន់ធ្ងរ ព្រោះវាត្រូវបានប្រើប្រាស់ដើម្បីបែងចែងអាសនៈទាំងអស់របស់គណបក្សសង្គ្រោះជាតិដែលត្រូវបានរំលាយ។

ចំណែកឯនៅឆ្នាំចុងក្រោយនៃនីតិកាលទី៥ (ឆ្នាំ ២០១៨)វិញ តាមការអង្កេតឃើញថា នៅបន្ទាប់ពីរំលាយ និងបែងចែកអាសនៈគណបក្សសង្គ្រោះជាតិទៅឱ្យគណបក្សដែលមិនទទួលអាសនៈក្នុងការបោះឆ្នោតឆ្នាំ២០១៣ និងគណបក្សកាន់អំណាច សកម្មភាពរបស់រដ្ឋសភាមានការធ្លាក់ចុះ បើប្រៀបធៀបនឹងឆ្នាំមុនៗនៃនីតិនេះ។ ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ មានចំនួនតិចតួច ហើយម្យ៉ាងវិញទៀតការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រភាគច្រើនគឺដើម្បីពង្រឹងអំណាចបក្សរបស់ខ្លួនតែប៉ុណ្ណោះ។ មួយវិញទៀត ចំពោះការបញ្ចេញមតិក្នុងសម័យប្រជុំនៃរដ្ឋសភារបស់តំណាងរាស្ត្រវិញ ពុំសូវឃើញមានអ្នកតំណាងរាស្ត្រឡើងពិភាក្សាសួរដេញដោលពីការ អនុម័តវិសោធនកម្ម និងការផ្តល់សច្ចាប័នលើច្បាប់នោះទេ។

**ការប្រជុំពេញអង្គរដ្ឋសភា ៖** នៅក្នុងនីតិកាលទី៥នេះ រដ្ឋសភាបានបើកសម័យប្រជុំរបស់ខ្លួនចំនួន១០លើក ដោយមាន១៣៩របៀបវារៈ។ ចំនួននេះមានការកើនឡើងចំនួន៩របៀបវារៈ ស្មើនឹង៧% បើប្រៀបធៀបនឹងនីតិកាលទី៤ ដោយក្នុងនីតិកាលទី៤រដ្ឋសភាបានបើកសម័យប្រជុំចំនួន៩លើក ដោយមាន១៣០របៀបវារៈ។ របៀបវារៈទាំងនោះរួមមាន ការវិសោធនកម្មច្បាប់នានាមានចំនួន១៨ ការឆ្លើយបំភ្លឺដោយក្រសួងពាក់ព័ន្ធនៅចំពោះមុខរដ្ឋសភាមានចំនួន២ ការបោះឆ្នោតដកអភ័យឯកសិទ្ធិមានចំនួន២ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តមានចំនួន១០ ការអនុម័តច្បាប់ស្តីពីការបង្កើតស្ថាប័នមានចំនួន៣ ការអនុម័តច្បាប់ស្តីពីហិរញ្ញវត្ថុ និងថវិកាជាតិមានចំនួន១១ ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានាមានចំនួន១៩ ការអនុម័តសេចក្តីព្រាង/សេចក្តីស្នើច្បាប់មានចំនួន៥០ និងរបៀបវារៈផ្សេងៗទៀតដូចជា ព្រះរាជសាររបស់ព្រះមហាក្សត្រ ឬការអានរបាយការណ៍ស្តីពីសកម្មភាពរដ្ឋសភា និងតំណាងរាស្ត្រជាដើម មានចំនួន២៣។

**ចំពោះការបញ្ចេញមតិរបស់តំណាងរាស្ត្រ ៖** ការសង្កេតឃើញថា នៅក្នុងនីតិកាលទី៥ មានតំណាងរាស្ត្រចំនួន ៥៨រូប បានឡើងបញ្ចេញមតិចំនួន២៩៦ដង ដោយប្រើរយៈពេលសរុបអស់ចំនួន២៥៨៦នាទី (ស្មើនឹង៤៣ម៉ោង៦នាទី) ។ រយៈពេលនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រមានការថយចុះ ៥៣៦១នាទី (៨៩ម៉ោង ២១នាទី) ស្មើនឹង ៦៧% បើ

ប្រៀបធៀបនឹងនីតិកាលទី៤ ដោយមានរយៈពេលសរុប ៧៩៤៧នាទី (ស្មើនឹង១៣២ម៉ោង២៧នាទី)។ តំណាងរាស្ត្រដែលបានបញ្ចេញមតិរួមមាន តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចមានចំនួន ៣០រូប បានបញ្ចេញមតិសរុបចំនួន១៨៦ដង ស្មើនឹង១៤៩០នាទី។ ចំណែកឯតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានចំនួន២៣រូប បានឡើងបញ្ចេញមតិសរុបចំនួន១០៣លើក ស្មើនឹង១០៤៩នាទី។ ដោយឡែកគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទទួលបាន៤១អាសនៈរបស់គណបក្សសង្គ្រោះជាតិ ក្រោយពីតុលាការកំពូលរំលាយ មានអ្នកតំណាងរាស្ត្រចំនួន៥រូប បានឡើងបញ្ចេញមតិសរុបចំនួន៧លើក ស្មើនឹង៤៧នាទី។

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ៖** នៅក្នុងនីតិកាលទី៥នេះ តាមទិន្នន័យដែលខុមហ្វ្រែលប្រមូលបានក្នុងរយៈពេលមួយអាណត្តិបង្ហាញឱ្យឃើញថា មានតំណាងរាស្ត្រចំនួន១៤៥រូប បានធ្វើសកម្មភាពចុះមូលដ្ឋានសរុបចំនួន ៧០០៣លើក ក្នុងគោលបំណងចុះសួរសុខទុក្ខចែកអំណោយ សម្ពោធសមិទ្ធផលនានា ចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សរបស់ខ្លួន អមដំណើរថ្នាក់ដឹកនាំ ចូលរួមវេទិកាសាធារណៈ រួមទាំងចុះជួយអន្តរាគមន៍ ឬដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋ។ ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រក្នុងនីតិកាលទី៥មានការធ្លាក់ចុះ ២២% បើប្រៀបធៀបនឹងនីតិកាលទី៤ (ឆ្នាំ២០០៨-២០១៣) ដោយនៅនីតិកាលទី៤ មានអ្នកតំណាងរាស្ត្របានចុះមូលដ្ឋានសរុប៨៧២៦លើក។ ការចុះមូលដ្ឋាននេះ មានអ្នកតំណាងរាស្ត្រដែលមកពីបីគណបក្ស គឺតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានចុះមូលដ្ឋានចំនួន៣៣១៥លើក (ចុះក្នុងមណ្ឌល២៣១១លើក ក្រៅមណ្ឌលបាន១០០៤លើក) តំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិបានចុះមូលដ្ឋានចំនួន៣៥៥២លើក (ក្នុងមណ្ឌលបាន១៩០៥លើក ក្រៅមណ្ឌលបាន១៦៤៧លើក) និងអ្នកតំណាងរាស្ត្រដែលមកពីគណបក្សហ្វ៊ុនស៊ិនប៉ិចបានចុះមូលដ្ឋានចំនួន១៣៦លើក (ក្នុងមណ្ឌលបានចំនួន៥៨លើក និងក្រៅមណ្ឌលបាន៧៨លើក)។

**ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រ ៖** នៅក្នុងនីតិកាលទី៥នេះ គណៈកម្មាធិការខុមហ្វ្រែលបានទទួលទិន្នន័យពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រមានចំនួន៥៩រូប ដែលក្នុងនោះលិខិតចេញដោយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាមានចំនួន៤រូប និងចេញពីតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិមានចំនួន៥៥រូប ដោយបានចេញលិខិតចំនួន៥៣៧ច្បាប់ជូនទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។ ការចេញលិខិតរបស់អ្នកតំណាងរាស្ត្រក្នុងនីតិកាលនេះ ឃើញមានការកើនឡើងជិតពីរដងបើប្រៀបធៀបនឹងនីតិកាលទី៤ ដោយក្នុងនីតិកាលទី៤មានអ្នកតំណាងរាស្ត្រ២៦រូបបានចេញលិខិតចំនួន២១១ច្បាប់ តែសម្រាប់នីតិកាលទី៥នេះ លិខិតរបស់អ្នកតំណាងរាស្ត្រមានការកើនរហូតដល់ ៣២៦លិខិត ស្មើនឹង ១៥០%។ ការសង្កេតរបស់ខុមហ្វ្រែលរកឃើញថា ក្នុងចំណោមទាំងនោះ មានលិខិតអន្តរាគមន៍ចំនួន១៦៥ច្បាប់ លិខិតអំពាវនាវស្នើចាត់វិធានការណ៍ចំនួន៣៦២ច្បាប់ លិខិតបញ្ចេញមតិចំនួន១ច្បាប់ លិខិតលើកជាសំណួរចំនួន២ច្បាប់ លិខិបំភ្លឺនៅរដ្ឋសភាចំនួន៦ច្បាប់ និងលិខិតឆ្លើយតប៦២ច្បាប់។

## សម្រាប់ព័ត៌មានបន្ថែម៖

| ឈ្មោះ | លេខទូរស័ព្ទ | |
|---|---|---|
| ១. លោក **គឹម ឈន** | នាយកប្រតិបត្តិស្ដីទី | ០១២ ៩៤២ ០១៩ |
| ២. លោក **កន សាវាង្ស** | អ្នកសម្របសម្រួលផ្នែកអង្កេត | ០១១ ៨៨ ៤៨ ៤០ |

__ទីស្នាក់ការកណ្ដាល__ ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**__Central Office__ : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : **comfrel@online.com.kh** **Website**: **www.comfrel.org**